NOM : **Évaluation en langue d'origine (cycle III) : KHMER**

DOCUMENT 2

សាលារៀនខុសគេ...

ព្រឹកស្អែកឡើង កូនធ្មប់ស្រីៗ ដើរជាជួរ ចូលក្នុងថ្នាក់ ដែលពួកគេត្រូវប្រលងវិញ្ញាសារល្បាយទិព្វ ។ ដូចរាល់ដង ពេលដែលមានការប្រលង គឺតែងតែមានការព្រួយបារម្ភ ។ ម្នាក់ៗសួរខ្លួនឯងថា តើបានរំលឹករូបមន្តក្នុងកម្មវិធី បានគ្រប់គ្រាន់ហើយរឺនៅ ។ អ្នកនៅក្បែរខ្ញុំ ដែលមានអាយុច្រើនជាងគេ ជាកូនធ្មប់តែម្នាក់គត់ ដែលមិនភ័យ ។ នាងតែងតែចេះគ្រប់មុខទាំងអស់ ហើយមិនចាត់ទុកថាវិញ្ញាសារនេះ សំខាន់ឡើយ ។ នាងលើកដៃឡើង :

- សុំទោស អ្នកគ្រូ តើយើងមានសិទ្ធិមើលកំណត់ត្រាមេរៀន របស់យើង ដែរ រឺទេ ?
- លឿនឡើង នាងៗ ! ចូលអង្គុយតាមកន្លែងរៀងៗខ្លួន ! អ្នកគ្រូបញ្ជាឡើង ។ ម្នាក់ៗ យកថូមួយ ហើយហាមជជែកគ្នា ។

នេះ ជាវិញ្ញាសារប្រលង អ្នកទាំងអស់គ្នាត្រូវធ្វើល្បាយដែលនាំឱ្យសើច ហើយហាមមើលសៀវភៅ ។ នាងខាងនោះ សូមបិទសៀវភៅភ្លាម! ចាប់ផ្ដើមធ្វើ ដោយស្ងៀមស្ងាត់ទៅ ពេលធ្វើហើយ នាងៗត្រូវភ្លក់ល្បាយខ្លួនឯងបន្តិចលមើល ដើម្បីពិនិត្យមើលប្រសិទ្ធិភាពរបស់វា ។ តោះ ចាប់ផ្ដើម !

ដោយ ជីល មូរហ្វី *នាងអាម៉ង់ដីន ម៉ាឡាបូល មេធ្មប់មិនប្រសព្វ*



សូមប្អូនឆ្លើយសំណួរខាងក្រោម ហើយគូសរង្វង់ជុំវិញចំលើយត្រឹមត្រូវ

១ អ្នកណា ជាអ្នកនិពន្ធអត្ថបទនេះ ?

នាងអាម៉ង់ដីន ម៉ាឡាបូល *ជីល មូរហ្វី* *លោកគ្រូ រឺអ្នកគ្រូ*

២ ហេតុអ្វីបានជាថ្នាក់រៀននេះ ខុសគេ ?

កូនសិស្ស នៅក្មេងណាស់ ។

គ្រូ តឹងរ៉ឹងជ្រុល ។

សិស្សទាំងអស់ គឺជាធ្មប់ ។

៣ តើកូនសិស្ស មានសិទ្ធិជួយគ្នាពេលប្រលងដែរ រឺទេ ?

បាទ រឺចាស *ទេ* *បានបន្តិចបន្តួច*

៤ តើគ្រូត្រួតពិនិត្យរបៀបម៉េច ដើម្បីឱ្យដឹងថាសិស្សម្នាក់ ប្រលងជាប់ ?

កូនសិស្សសើចក្អាកក្អាយ ។

កូនសិស្សនៅស្ងៀមស្ងាត់ ។

កូនសិស្សចាប់ផ្ដើមជជែកគ្នា ។

…../2 + …../2 + …../2 + …../2 + = …../8